# សៀវភៅណែនាំ ស្តីពី
# "លទ្ធកម្មសាធារណៈ"




## តោះ! ស្វែងយល់ពីការដេញថ្លៃសាធារណៈទាំងអស់គ្នា

# អារម្ភកថា

មិត្តអ្នកអានជាទីគោរព!

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៥ ចែងថា “ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។” និងមាត្រា៤១ ចែងថា “ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ...។ ” បន្ថែមទៅលើនេះទៀត រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំយុទ្ធសាស្ត្រចតុកោណដែលមានអភិបាលកិច្ចល្អជាមូលដ្ឋានគ្រឹះនៃយុទ្ធសាស្ត្រទាំងឡាយរបស់រាជរដ្ឋាភិបាល។ អភិបាលកិច្ចល្អត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋនៅគ្រប់ស្រទាប់ និងគ្រប់ដំណាក់កាលនៃការគ្រប់គ្រងរដ្ឋ។ រាជរដ្ឋាភិបាលកម្ពុជាក៏បានរៀបចំ និងអនុវត្តផែនការកំណែទំរង់រដ្ឋបាលសាធារណៈ ដោយដាក់ឲ្យអនុវត្តនូវកម្មវិធីវិមជ្ឈការដែលមានការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិខិតជិតជាមួយពលរដ្ឋ ក្នុងការសម្រេចចិត្ត និងផ្តល់ឱកាសឲ្យគាត់ចូលរួមតាមដានកិច្ចអភិវឌ្ឍមូលដ្ឋានដើម្បីលើកកម្ពស់ ជីវភាពរបស់គាត់។

កូនសៀវភៅត្លុក “លទ្ធកម្មសាធារណៈ” ជាសៀវភៅអប់រំបែបរូបភាពថ្មីមួយទៀត ដើម្បីចូលរួមចំណែកផ្តល់ចំណេះដឹង ដល់សាធារណជនយល់ដឹងពីការអភិវឌ្ឍ និងការចូលរួមរបស់ពលរដ្ឋ ក្នុងដំណើរការលទ្ធកម្ម

(ដេញថ្លៃ) សារធារណៈ ដែលជាឧបករណ៍មួយ ជួយជម្រុញឲ្យការអភិវឌ្ឍ មានប្រសិទ្ធិភាព ក៏ដូចជា ជ្រោមជ្រែងដល់ការអនុវត្តការងាររបស់អាជ្ញាធររដ្ឋ និង អ្នកជាប់កាតព្វកិច្ចក្នុងអភិបាលកិច្ចធនធានរបស់រដ្ឋជាមួយវិស័យឯកជន ក្នុងការអនុវត្តកិច្ចការងារសាធារណៈ ប្រកបដោយវិជ្ជាជីវៈ តម្លាភាព និងគិតដល់ផលប្រយោជន៍សាធារណៈជាចម្បង។

ខ្លឹមសារសំខាន់ៗនៅក្នុងកូនសៀវភៅនេះ នឹងបង្ហាញមិត្តអ្នកអានពីទស្សនទាន និងដំណើរការលទ្ធកម្មសាធារណៈក្នុងកិច្ចអភិវឌ្ឍ និងឱកាសដែលអាចឲ្យពលរដ្ឋចូលរួមយ៉ាងសកម្មជាមួយរដ្ឋ ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការកសាងសង្គមកម្ពុជាយើងក្លាយទៅជាសង្គមល្អមួយបាន។

ក្នុងក្របខណ្ឌនៃការអភិវឌ្ឍជាសកល ដើម្បីបានសង្គមល្អមួយគឺសង្គមនោះត្រូវមានការអភិវឌ្ឍ បែបលទ្ធិប្រជាធិបតេយ្យ ដែលតម្រូវឲ្យមានការគ្រប់គ្រងរដ្ឋផ្អែកលើគោលការណ៍អភិបាលកិច្ចល្អ ។ ទន្ទឹមគ្នានេះដែរ ធាតុសំខាន់ដើម្បីឲ្យបានអភិបាលកិច្ចល្អគឺ ត្រូវមានគណនេយ្យភាពជាមុនសិនដែលវាកើតឡើងបានតាមរយៈគណនេយ្យភាពសង្គម។ គណនេយ្យភាពសង្គមមានន័យថា ជាយន្តការដែលពលរដ្ឋអនុវត្តដើម្បីចូលរួមធ្វើឲ្យអាជ្ញាធរអនុវត្តភារកិច្ចប្រកបដោយតម្លាភាព ការឆ្លើយតប និងមានការទទួលខុសត្រូវខ្ពស់។ លទ្ធកម្មសារធារណៈ ជាយន្តការមួយនៃគណនេយ្យភាពសង្គម យើងអាចសរុបជារួមបានថា ការធ្វើលទ្ធកម្មសារធារណៈបានល្អ នឹងជម្រុញឲ្យយើងមានសង្គមល្អមួយ ដែលប្រជាពលរដ្ឋនឹងទទួលបាននូវតម្រូវការជាមូលដ្ឋានរបស់ខ្លួន ដោយសមធម៌ និងយុត្តិធម៌ ដោយមានការយកចិត្តទុកដាក់ និងចែករំលែកគ្នាទៅវិញទៅមកក្នុងការពង្រឹងជីវភាពរស់នៅរបស់ខ្លួន។

# មាតិកា


១. យល់ដឹងពីការអភិវឌ្ឍ

២. កត្តារាំងស្ទះដល់ការអភិវឌ្ឍ

៣. លទ្ធកម្មសាធារណៈ

៤. ការចូលរួមរបស់ពលរដ្ឋ

# តួអង្គសំខាន់ៗ



១. ទន្សាយ តំណាងឲ្យ អ្នកមានចំនេះដឹង និងប្រាជ្ញាវៃឆ្លាត

២. ប្រជាពលរដ្ឋ ជាអ្នក ទាមទារសេវា និងទទួល សេវាមូលដ្ឋានពីរដ្ឋ





៣. អាជ្ញាធរ ជាអ្នកផ្តល់ សេវាជូនពលរដ្ឋ

៤. អ្នកទទួលការ ឬម៉ៅការ ជាផ្នែក ឯកជន ទទួល ការអនុវត្តគម្រោងរបស់រដ្ឋ



# ផ្នែកទី ១

# យល់ដឹងពីការអភិវឌ្ឍ



ការអភិវឌ្ឍផ្តោតសំខាន់លើ៖

- **អភិវឌ្ឍផ្នែកសង្គម** មានសេវាអប់រំ សុខភាព អនាម័យ ប្រព័ន្ធគ្រប់គ្រងរដ្ឋ ។ល។

- **អភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធ** មានស្ពាន ថ្នល់ សាលារៀន វត្តអារាម មន្ទីរពេទ្យ សំណង់ អគារផ្សេងៗ ។ល។


ហេតុអ្វីបានជាការអភិវឌ្ឍឃុំនេះមិនល្អ?


ឃុំទាំងពីរនេះប្រើមូលនិធិឃុំមកអភិវឌ្ឍ
ប្រហែលគ្នា ហេតុអ្វីឃុំនេះល្អជាង ?



ប្រភពថវិកាសម្រាប់អភិវឌ្ឍ ជាថវិការបស់យើងទាំងអស់គ្នាបានមកពី:

- ពន្ធ (ពន្ធអាករ និងពន្ធនាំចេញ-ចូល)
- ជំនួយដៃគូអភិវឌ្ឍ
- កម្ចីអន្តរជាតិដែលយើងជាអ្នកសង
- បដិភាគថវិកាពីពលរដ្ឋ
- ចំណូលពីទេសចរណ៍ យករ៉ែ ឬធនធានធម្មជាតិផ្សេងៗ

ដូច្នេះយើងត្រូវប្រើប្រាស់វាឲ្យមានប្រសិទ្ធភាព

**ប្រសិទ្ធភាព មានន័យថា បានផលគាប់ប្រសើរ និងសន្សំសំចៃ**



**ការអភិវឌ្ឍល្អ** គឺមានន័យថា រាល់គម្រោងសាងសង់ និងការផ្តល់សេវាអ្វីមួយរបស់រដ្ឋ អស់ថវិកាតិច គម្រោងមានគុណភាព ចំទិសដៅ និងបំរើផលប្រយោជន៍រួម។ **ការអភិវឌ្ឍល្អ** គឺត្រូវ មានការចូលរួមពីពលរដ្ឋ និងអនុវត្តតាមគោលការណ៍ច្បាប់។

# កត្តារាំងស្ទះការអភិវឌ្ឍ



# កត្តារាំងស្ទះដល់ការអភិវឌ្ឍ ភូមិ ឃុំ របស់យើង




**ខ្វះគុណភាពនិងបច្ចេកទេស** ឧទា. ការសាងសង់ផ្លូវ អាគារ លូរំដោះទឹកភ្លៀង និងទឹកស្អុយជាដើម ដែល៖

- មិនមានគុណភាព
- មិនត្រូវតាមគម្រោង
- មិនមានការចូលរួមពីពលរដ្ឋក្នុងការត្រួតពិនិត្យ
- មានការកេងប្រវ័ញ្ច សម្ភារៈ និងឧបករណ៍សំណង់
- ការពន្យាពេលសាងសង់យូរពេក




១. បញ្ហាគ្រោះធម្មជាតិ មិនអាចបញ្ចៀសបានទេ ប៉ុន្តែ យើងអាចត្រៀមលក្ខណៈ បង្ការផលប៉ះពាល់ធ្ងន់ធរបាន

២. បញ្ហាខ្វះការថែទាំ យើងអាចដោះស្រាយបាន ដោយយើងទាំងអស់គ្នា ចូលរួមពិនិត្យ និងថែទាំ ព្រោះជាសម្បត្តិរួម

៣. បញ្ហាខ្វះគុណភាព និងបច្ចេកទេសក្នុងការសាងសង់ គឺត្រូវធ្វើលទ្ធកម្មសាធារណៈ ឲ្យបានត្រឹមត្រូវ។

**អ្វីទៅជា លទ្ធកម្មសាធារណៈ ? ? ?**



# ការប្រើប្រាស់មូលនិធិឃុំ សង្កាត់ គ្មានប្រសិទ្ធិភាព






“មិនថាមានធនធានច្រើនប៉ុណ្ណាទេ វានឹងមិនចេះគ្រប់គ្រាន់ឡើយបើយើងមិនគ្រប់គ្រងវាឲ្យមានប្រសិទ្ធភាព និងអស់លទ្ធភាព” ដូច្នេះត្រូវគ្រប់គ្រងមូលនិធិឃុំឲ្យបានល្អ ទើបឃុំយើងអភិវឌ្ឍល្អ។

# ផ្នែកទី ៣

# លទ្ធកម្មសាធារណៈ






**លទ្ធកម្មសាធារណៈ:** ជាដំណើរការទិញទំនិញ, ជួលសេវាកម្ម និងគំរោងសាងសង់ជាសាធារណៈ ដែលមានតំលៃសមរម្យបំផុត ប្រកបដោយគុណភាព និងបរិមាណ ទាន់ពេលវេលា មានធនធានគ្រប់គ្រាន់។

យើងធ្វើលទ្ធកម្មសាធារណៈដើម្បីធានាថា ការជ្រើសរើសអ្នកម៉ៅការមកសាងសង់គម្រោង មានសមត្ថភាព អាចធ្វើការងារ មានគុណភាព និងប្រើប្រាស់ថវិកាដោយសន្សំសំចៃ ដើម្បីជាប្រយោជន៍សហគមន៍មូលដ្ឋានយូរអង្វែង។

# លទ្ធកម្មសាធារណៈចែកជា៣ដំណាក់កាល

## ១. មុនពេលដេញថ្លៃ

ក្រុមការងារបច្ចេកទេសចុះសិក្សា វាយតំលៃផលប៉ះពាល់ និងដោះស្រាយសំណាង ជូនពលរដ្ឋដោយមានការចូលរួម



ប្រកាសផ្សាយព័ត៌មានពីការដេញថ្លៃជាសាធារណៈ

http://www.ncdd.gov.kh/km/media-center/jobs-procurement




សាលាឃុំ

ប្រកាសដេញថ្លៃគម្រោង





## ២. ពេលដេញថ្លៃ




ក្នុងគម្រោងមួយត្រូវមានអ្នកម៉ៅការយ៉ាងតិចបីនាក់មកពីក្រុមហ៊ុនខុសៗគ្នាប្រកួតប្រជែងដេញថ្លៃដោយត្រឹមត្រូវ។ អ្នកម៉ៅការណាមួយដាក់តំលៃ លើការសាងសង់ទាបជាងគេ នឹងទទួលបានគម្រោងយកទៅអនុវត្ត។

**ដើម្បីចូលរួមដេញថ្លៃបាន អ្នកម៉ៅការត្រូវចុះបញ្ជីអ្នកទទួលការដើម្បីសុំសិទ្ធិដេញថ្លៃ និងទទួលស្គាល់ពីរដ្ឋជាមុនសិន**

## ៣. ពេលអនុវត្តគម្រោង



- អ្នកទទួលការអនុវត្តគម្រោងត្រូវ គោរពតាមកិច្ចសន្យារបស់ខ្លួន ធានាគុណភាពនៃការសាងសង់ និងទាន់ពេលវេលា។
- គណៈកម្មការត្រួតពិនិត្យគម្រោងចុះពិនិត្យ និងផ្ទៀងផ្ទាត់ លើការអនុវត្តកិច្ចសន្យារបស់អ្នកម៉ៅការ
- ប្រជាពលរដ្ឋអាចចូលរួមពិនិត្យមើលការអនុវត្តកិច្ចសន្យារបស់ អ្នកទទួលការ និងជូនដំណឹងដល់គណៈកម្មការទទួលបន្ទុក លទ្ធកម្មស្រុក ក្រុង និងខេត្តនូវភាពមិនប្រក្រតីនិងលទ្ធផល ការងារគម្រោង។

# លទ្ធកម្មគ្មានតម្លាភាព



# ការអនុវត្តគម្រោងមិនល្អ




យើញទេ គម្រោងនេះអនុវត្តពិតប្រាកដ អស់ថវិកាតែ ៦០ទៅ៨០ ភាគរយប៉ុណ្ណោះ។ លុយទឹកតែ និងចំណាយផ្សេងៗអស់ពី ២០ទៅ៤០ ភាគរយទៀត។

(ប្រភព: អ្នកសង្កេតការស្ម័គ្រចិត្តតាមភូមិ)



# សីលធម៌ ក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈ

**សីលធម៌ សម្រាប់សមាជិកនៃគណៈកម្មការលទ្ធកម្ម៖**

- មិនត្រូវមាននរណាម្នាក់អាចយកកម្រៃ រួមមានលុយកាក់ សម្ភារៈ ពីអ្នកខាងក្រៅ អ្នកដេញថ្លៃ ឬទីប្រឹក្សាក្រៅពីប្រាក់ខែខ្លួនបានទេ។
- ត្រូវរាយការណ៍ភ្លាម នូវអំពើឆបោក ពុករលួយ ឃុបឃិត និង គំរាមកំហែងនានា
- មិនត្រូវមានទំនាស់ផលប្រយោជន៍នៅពេលធ្វើការសម្រេចចិត្ត។

**សីលធម៌សម្រាប់អ្នកដេញថ្លៃ និងទីប្រឹក្សាខេត្តដែលចូលរួមមាន៖**

- មិនត្រូវមានទំនាក់ទំនងជាមួយអ្នកដែលមានទំនាស់ផលប្រយោជន៍
- ត្រូវប្រកាសកាលបើខ្លួនមានទំនាស់ផលប្រយោជន៍ នឹងអ្នកអនុវត្តលទ្ធកម្ម។
- មិនត្រូវប្រព្រឹត្តអំពើពុករលួយ ក្លែងបន្លំ ឃុបឃិត និងគំរាម ពាក់ព័ន្ធ នឹងការដេញថ្លៃនោះទេ។
- ត្រូវបើកចំហរដល់ទីភ្នាក់ងាររបស់រដ្ឋ ឬដៃគូអភិវឌ្ឍន៍ ក្នុងការពិនិត្យ ឯកសារពាក់ព័ន្ធនឹងការដេញថ្លៃ ទោះជាការដេញថ្លៃនោះ ទទួលបាន ជោគជ័យ ឬអត់ក៏ដោយ។
- មិនត្រូវឲ្យលុយកាក់ទៅនរណាម្នាក់ ដែលពាក់ព័ន្ធនឹងលទ្ធកម្ម រួមមានសាច់ញាតិ ឬមិត្តភក្តិ។

**សីលធម៌ ក្នុងប្រព័ន្ធទាំងឡាយគឺតែងធ្វើក្នុងទម្រង់ការប្រកាសពីសីលធម៌**

- ទម្រង់សេចក្តីប្រកាសរួមមានសីលធម៌សម្រាប់អ្នកដែលពាក់ព័ន្ធ ឲ្យអាន និងចុះហត្ថលេខា មុននឹងចាប់ផ្តើមការងារ ឬអនុវត្តលទ្ធកម្ម។

# ផ្នែកទី ៤

# ការចូលរួមរបស់ពលរដ្ឋ

ក្នុងគោលការណ៍គណនេយ្យភាពសង្គម និងការអភិវឌ្ឍ
តាមបែបលទ្ធិប្រជាធិបតេយ្យ ទាំងអាជ្ញាធរ និងពលរដ្ឋ
ត្រូវសហការ និងចូលរួមយ៉ាងសកម្មក្នុងកិច្ចការអភិវឌ្ឍ
ប្រទេស និងមូលដ្ឋាន និងទទួលខុសត្រូវរាល់សមិទ្ធផល
ឬទង្វើដែលខ្លួនបានប្រព្រឹត្តៗ



# ភាគព្វកិច្ចពលរដ្ឋក្នុងកិច្ចអភិវឌ្ឍសង្គម



# ផ្នែកផ្សេងៗនៃសង្គម

១. សង្គមស៊ីវិល (ពលរដ្ឋ, អង្គការមូលដ្ឋាន, សមាគម, ។ល។)
២. ភ្នាក់ងាររដ្ឋ (ក្រុមប្រឹក្សា មន្ត្រីសាធារណៈ គណៈអភិបាល។ល។)
៣. ផ្នែកឯកជន (អាជីវករ អ្នកទទួលការ ឬម៉ៅការ)

យោងរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាមាត្រា៣៥ ចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យនិងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។" និងមាត្រា៤១ចែងថា "ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ...។"



# ឱកាសនៃការចូលរួមរបស់ពលរដ្ឋក្នុងកិច្ចអភិវឌ្ឍ

យន្តការមានស្រាប់:

**អាជ្ញាធរ ឬអ្នកផ្តល់សេវាជាអ្នករៀបចំសម្រាប់ឲ្យពលរដ្ឋចូលរួមក្នុង៖**

- ការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ
- ការប្រជុំពិគ្រោះយោបល់តាមភូមិលើផែនការអភិវឌ្ឍឃុំ/សង្កាត់
- វេទិកាពិគ្រោះយោបល់ថ្នាក់ឃុំ/សង្កាត់របស់ក្រុមប្រឹក្សាក្រុង (គ្រោង និងធ្វើ)។
- សមាហរណកម្មផែនការវិនិយោគប្រចាំឆ្នាំរបស់ឃុំ/សង្កាត់
- កិច្ចប្រជុំស្តីពីការអភិវឌ្ឍឃុំ/សង្កាត់

យន្តការផ្តួចផ្តើមដោយពលរដ្ឋ/សង្គមស៊ីវិល ដូចជាសកម្មភាពប្រមូលផ្តុំរបស់ពលរដ្ឋដើម្បីទាមទារឲ្យមានការឆ្លើយតបពីរដ្ឋ៖

- យុទ្ធនាការ
- ការតវ៉ាដោយអហិង្សា
- សារព័ត៌មាន/ប្រព័ន្ធផ្សព្វផ្សាយ




CIPE

គាំទ្រថវិកាដោយ CIPE

SILAKA

ផ្ទះលេខ ៥៥B-៥៥C ផ្លូវ៣៩០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ(៨៥៥)២៣ ២១៧ ៨៧២/២១០ ៩០២ ទូរស័ព្ទដៃ(៨៥៥)១២ ៧៩ ២៣ ៧៩
E-mails: silaka@silaka.org / website:www.silaka.org